# ដំណោះស្រាយការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់គ្នា

## សំណួរដែលគេសួរជាញឹកញាប់អំពីការបោះឆ្នោតតាមសំបុត្រ (VBM)

### តើសន្លឹកឆ្នោត VBM ថ្មីមានលក្ខណៈដូចម្ដេច?

សន្លឹកឆ្នោត VBM នឹងជាប័ណ្ណសន្លឹកឆ្នោតពេញលេញដែលមានគ្រប់ព័ត៌មានដែលត្រូវការដើម្បីបោះឆ្នោត ។ ដោយអាស្រ័យលើទំហំនៃការបោះឆ្នោត និងចំនួននៃការប្រកួតប្រជែងនៅលើសន្លឹកឆ្នោត កញ្ចប់ VBM អាចនឹងមានផ្ទុកប័ណ្ណច្រើនសន្លឹកដែលមានការប្រកួតប្រជែងនៅលើទំព័រមុខនិងខាងក្រោយ ។

បើអ្នកស្នើសុំសម្ភារៈការបោះឆ្នោតជាភាសាផ្សេងពីភាសាអង់គ្លេស អ្នកនឹងទទួលបានសន្លឹកឆ្នោត VBM ជាភាសាដែលអ្នកបានស្នើសុំ ។




### តើស្រោមសំបុត្រ VBM ថ្មីមានលក្ខណៈដូចម្ដេច?

ស្រោមសំបុត្រ VBM ដែលចេញដោយការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles នឹងនៅតែមានត្រានៅលើវាដែលសរសេរថា ៖ សំបុត្រការបោះឆ្នោតផ្លូវការដែលអនុញ្ញាតដោយសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក ។ បន្ថែមពីលើនេះ អ្នកនឹងឃើញត្រារបស់ខោនធីនៅលើគ្រប់ស្រោមសំបុត្រ ។ សម្រាប់សំណួរឬកង្វល់នានាពាក់ព័ន្ធនឹង VBM សូមទូរសព្ទទៅលេខ 1-800-815-2666 ជម្រើស 2 ។

### តើខ្ញុំស្នើសុំសន្លឹកឆ្នោត VBM ជាភាសាផ្សេងពីភាសាអង់គ្លេសដោយរបៀបណា?

សូមទូរសព្ទទៅផ្នែកសេវាពហុភាសារបស់មន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles តាមរយៈលេខ (800) 815-2666 ជម្រើស 3 ដើម្បីស្នើសុំសម្ភារៈការបោះឆ្នោតជាភាសាមួយផ្សេងទៀត ។

### តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោត VBM ដោយរបៀបណា?

អ្នកអាចស្នើសុំសន្លឹកឆ្នោត VBM តាមអ៊ីនធឺណិតតាមរយៈគេហទំព័រ LAvote.net ឬដោយបំពេញក្រុបខាងក្រោយនៃកូនសៀវភៅសន្លឹកឆ្នោតគំរូ ហើយបញ្ជូនវាត្រឡប់ទៅការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles វិញ ។

### តើខ្ញុំត្រូវតែបញ្ជូនត្រឡប់ទៅវិញនូវប័ណ្ណសន្លឹកឆ្នោតទាំងអស់ដើម្បីឱ្យជម្រើសនានារបស់ខ្ញុំត្រូវបានគេរាប់មែនឬទេ?

ទេ អ្នកអាចបញ្ជូនត្រឡប់ទៅវិញតែប័ណ្ណសន្លឹកឆ្នោតណាដែលអ្នកចង់បោះឆ្នោតនៅលើនោះ ។ សូមចងចាំថា ការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles នឹងរាប់តែប័ណ្ណណាដែលអ្នកបញ្ជូនត្រឡប់មកវិញប៉ុណ្ណោះ ។ ការមិនបញ្ជូនត្រឡប់ទៅវិញនូវប័ណ្ណសន្លឹកឆ្នោតទាំងអស់ នឹងមិនប៉ះពាល់ដល់ប័ណ្ណដែលអ្នកបានផ្ញើមកវិញដោយរបៀបណាមួយឡើយ ។

### តើខ្ញុំគួរធ្វើអ្វី បើខ្ញុំធ្វើឱ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោត VBM របស់ខ្ញុំ?

បើអ្នកធ្វើឱ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោតរបស់អ្នកមួយឬច្រើន អ្នកអាចស្នើសុំសម្ភារៈប្តូរថ្មីរហូតដល់ 7 ថ្ងៃមុនដល់ថ្ងៃបោះឆ្នោត ។ បើការប្តូរថ្មីមួយត្រូវបានស្នើសុំ យើងខ្ញុំនឹងផ្ញើជូនកញ្ចប់ VBM ថ្មីស្រឡាង ។ បើមានរយៈពេលតិចជាង 7 ថ្ងៃមុនថ្ងៃបោះឆ្នោតនោះ សូមទាក់ទងមកការិយាល័យយើងខ្ញុំតាមរយៈលេខ (800) 815-2666 ជម្រើស 2 ។

# ដំណោះស្រាយការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់គ្នា

## សំណួរដែលគេសួរជាញឹកញាប់អំពីការបោះឆ្នោតតាមសំបុត្រ (VBM)

**តើខ្ញុំគួរធ្វើអ្វីជាមួយនឹងឈុតសម្ភារៈ VBM ដំបូងរបស់ខ្ញុំ បើខ្ញុំបានស្នើសុំឈុតថ្មីហើយនោះ?**

សូមសរសេរ "មោឃៈ (Void)" នៅលើសម្ភារៈចាស់ទាំងអស់ ហើយបោះពួកវាចោល ។

---

**តើមានអ្វីកើតឡើង បើហត្ថលេខានៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញមិនមាន ឬមិនត្រូវគ្នានឹងហត្ថលេខានៅលើឯកសារតម្កល់?**

ការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles នឹងផ្ញើតាមសំបុត្រនូវទម្រង់ពាក្យសម្បថសន្លឹកឆ្នោត ដែលមិនទាន់ចុះហត្ថលេខា ដើម្បីអោយអ្នកបំពេញនិងចុះហត្ថលេខា ។ អ្នកនឹងមានពេលរហូតដល់ទៅ 8 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនត្រឡប់នូវទម្រង់ពាក្យនោះទៅការិយាល័យរបស់យើងខ្ញុំដើម្បីឱ្យសន្លឹកឆ្នោតរបស់អ្នកត្រូវគេបានរាប់ ។

---

**តើខ្ញុំអាចតាមដានសន្លឹកឆ្នោត VBM បានដែរឬទេ?**

បាន ដូចដែលដំណើរការ VBM បច្ចុប្បន្នរបស់យើងខ្ញុំដែរ អ្នកបោះឆ្នោតអាចតាមដានសន្លឹកឆ្នោតរបស់ពួកគេតាមអ៊ីនធឺណិតនៅលើគេហទំព័រ LAvote.net ។

---

**តើខ្ញុំអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់ខ្ញុំទៅវិញដោយរបៀបណា?**

អ្នកអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់អ្នកទៅវិញ តាមរយៈសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក (USPS) ដោយភ្ជាប់តែមប្រៃសណីយ៍ដែលចាំបាច់ ។ បើអ្នកចង់បញ្ជូនវាដោយផ្ទាល់មកយើងខ្ញុំ អ្នកអាចទម្លាក់វានៅទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយ ឬទីកន្លែងបោះឆ្នោតណាមួយក៏បាន ។ មិនថាអ្នកបញ្ជូនត្រឡប់វាទៅវិញតាមរបៀបណានោះទេ សូមកុំភ្លេចចុះហត្ថលេខានិងកាលបរិច្ឆេទនៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញរបស់អ្នក ។

---

**តើសន្លឹកឆ្នោត VBM ចាប់ផ្តើមផ្ញើតាមសំបុត្រនៅពេលណា?**

យើងខ្ញុំចាប់ផ្តើមផ្ញើរចេញសន្លឹកឆ្នោត VBM តាមសំបុត្ររយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះជា VBM អចិន្ត្រៃយ៍ នឹងចាប់ផ្តើមទទួលបានសន្លឹកឆ្នោតរបស់ពួកគេប៉ុន្មានថ្ងៃបន្ទាប់ពីការផ្ញើតាមសំបុត្រ ។ ការស្នើសុំតែមួយដង នឹងត្រូវបានដំណើរការប្រចាំថ្ងៃ ហើយគួរទទួលបានក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការស្នើសុំ ។

---

**តើខ្ញុំត្រូវការអ្វីដើម្បីបំពេញសន្លឹកឆ្នោត VBM?**

សន្លឹកឆ្នោត VBM ត្រូវតែបំពេញដោយប្រើប៊ិចទឹកខ្មៅឬខៀវ ។

---

**តើតែមប្រៃសណីយ៍ប៉ុន្មានដែលខ្ញុំត្រូវការដើម្បីផ្ញើសន្លឹកឆ្នោតរបស់ខ្ញុំតាមរយៈ USPS?**

សម្រាប់ការបោះឆ្នោតភាគច្រើន អ្នកនឹងត្រូវការតែមចំណាត់ថ្នាក់ទីមួយចំនួនមួយ ដើម្បីផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់វិញតាមសំបុត្រ ។ យើងខ្ញុំនឹងរួមបញ្ចូលព័ត៌មាននិងសេចក្តីណែនាំបន្ថែមនៅក្នុងកញ្ចប់ VBM របស់អ្នក បើតែមប្រៃសណីយ៍បន្ថែមតម្រូវឲ្យមាននោះ ។

---

**តើខ្ញុំអាចស្វែងយល់បន្ថែមអំពីបទពិសោធន៍ VBM ថ្មីនៅកន្លែងណា?**

សូមចូលទៅកាន់ VSAP.lavote.net ដើម្បីស្វែងយល់បន្ថែមអំពីការស្រាវជ្រាវ និងការរៀបចំដែលបញ្ចូលទៅក្នុងបទពិសោធន៍ VBM ថ្មីនោះ ។